**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ៥៦៥៨ ព.ណ...សរ.វ

ថ្ងៃ ចន្ទ ៩ រោច ខែ មិគសិរ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ

- យោងប្រកាសអន្តរក្រសួងលេខ១៧២ពណ. អវង.ប្រក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល ស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា
- យោងលើការព្រមព្រៀង លើរូបមន្តកំណត់តម្លៃជាមួយក្រុមហ៊ុនប្រេងឥន្ធនៈដែលប្រកបអាជីវកម្មនៅកម្ពុជា
- យោងការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារក្នុងតំបន់ និងអន្តរជាតិ

ផ្អែកតាមតម្លៃមធ្យមប្រេងឥន្ធនៈលើទីផ្សារអន្តរជាតិ ថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី០១ ដល់១៥ ខែមករា ឆ្នាំ២០១៩ នឹងត្រូវលក់ ៣.៣៧៣រៀល/១លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.៣៦០រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត។

ដើម្បីជួយសម្រួលដល់ជីវភាពរបស់ប្រជាជន និងដោយមានការរួមចំណែកពីក្រុមហ៊ុនចែកចាយប្រេងឥន្ធនៈនៅកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចបញ្ចុះតម្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា ចំនួន៤សេនដុល្លារ/លីត្រ ។

ដូច្នេះថ្លៃលក់រាយប្រេងឥន្ធនៈសម្រាប់អនុវត្ត **ចាប់ពីថ្ងៃទី០១ ដល់ ១៥ ខែមករា ឆ្នាំ២០១៩** នឹងចុះមក ៣.២០០ រៀល/លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.២០០ រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត ។

ការគណនាថ្លៃលក់រាយប្រេងឥន្ធនៈមានលម្អិតដូចតារាងខាងក្រោម៖

**តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារកម្ពុជា**

| ល.រ | អធិប្បាយ | ប្រេងសាំងធម្មតា/លីត្រ (Gasoline 92) | ប្រេងម៉ាស៊ូត/លីត្រ (Gasoil) |
|---|---|---|---|
| ១ | **Average MOPS** | 0,៣៤៧៦ ដុល្លារ | 0,៤២0៧ ដុល្លារ |
| ២ | **ពន្ធ៖** | 0,១៧៩១ ដុល្លារ | 0,0៦៥៦ ដុល្លារ |
| | ពន្ធគយ | 0,0៧២៦ ដុល្លារ | 0,0000 ដុល្លារ |
| | អាករបន្ថែម | 0,0២00 ដុល្លារ | 0,0៤00 ដុល្លារ |
| | អាករពិសេស | 0,0៨៦៥ ដុល្លារ | 0,0២៥៦ ដុល្លារ |
| ៣ | **PREMIUM** | 0,២0 ដុល្លារ | 0,២៣ ដុល្លារ |
| ៤ | អាករលើតម្លៃបន្ថែម (១0% នៃ ១+២+៣) | 0,0៧២៧ ដុល្លារ | 0,0៧២0 ដុល្លារ |
| ៥ | ថ្លៃលក់រាយ/លីត្រ (គិតជាដុល្លារ) | 0,៧៩៩៣ ដុល្លារ | 0,៧៩២៣ ដុល្លារ |
| ៦ | ថ្លៃលក់រាយ/លីត្រ (គិតជារៀល) | ៣.២១២ រៀល | ៣.១៨៤ រៀល |
| ៧ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជាដុល្លារ) | 0,៨0 ដុល្លារ | 0,៧៩ ដុល្លារ |
| ៨ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជារៀល) | ៣.២00 រៀល | ៣.២00 រៀល |

សម្គាល់៖ អត្រាប្តូរប្រាក់ផ្លូវការ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ដែលស្មើនឹង ៤0១៨រៀល/ដុល្លារអាមេរិក

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

## តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ

| ថ្ងៃខែឆ្នាំ | ប្រេងសាំងធម្មតា/ធុង EA 92 (USD/Barrel) | ប្រេងម៉ាស៊ូត/ធុង Gasoil (USD/Barrel) |
|---|---|---|
| ១៧ ធ្នូ ២០១៨ | ៥៩,៦២ | ៧១,៥១ |
| ១៨ ធ្នូ ២០១៨ | ៥៧,៩៥ | ៦៩,៨០ |
| ១៩ ធ្នូ ២០១៨ | ៥៥,៩៣ | ៦៧,៩៦ |
| ២០ ធ្នូ ២០១៨ | ៥៥,១៨ | ៦៧,៥៩ |
| ២១ ធ្នូ ២០១៨ | ៥៤,១៥ | ៦៦,២០ |
| ២៦ ធ្នូ ២០១៨ | ៥១,៣១ | ៦២,០៨ |
| ២៧ ធ្នូ ២០១៨ | ៥៤,១៩ | ៦៥,៤១ |
| ២៨ ធ្នូ ២០១៨ | ៥៣,៧៨ | ៦៤,៥៩ |
| មធ្យមភាគ ០៨ថ្ងៃ | ៥៥,២៦៣៨ | ៦៦,៨៩២៥ |
| មធ្យមភាគ (ដុល្លារ/លីត្រ) | ០,៣៤៧៦ | ០,៤២០៧ |

សូមបញ្ជាក់ថា ក្រសួងពាណិជ្ជកម្មមិនមែនជាអ្នកកំណត់ថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាទេ គឺក្រសួងគ្រាន់តែស្រង់តម្លៃឡើង-ចុះ នៃប្រេងតាមទីផ្សារអន្តរជាតិ មកគណនាតាមប្រកាសដូចមានក្នុងឯកសារយោងខាងលើតែប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ សូមសាធារណៈជនមេត្តាជ្រាបជាព័ត៌មាន និងសូមគ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ប្រតិបត្តិតាមការចាំបាច់ ។

ព្រះរាជាណាចក្រកម្ពុជា * ក្រសួងពាណិជ្ជកម្ម *